# សេចក្តីថ្លែងការណ៍របស់ នួន ជា ទៅកាន់តុលាការ ខណៈពេលដែលអង្គជំនុំជម្រះស្តាប់សក្ខីកម្មសាក្សីពីររូប

**ដោយ ខេលី ឌូព្រី អេនច្រូ**

**ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២**

*ប្រែសម្រួលដោយ និត្យ ធរន្ធារាណា*

នៅថ្ងៃពុធ ទី២០ ខែមិថុនា ឆ្នាំ២០១២ សមាជិកនៃអង្គជំនុំជម្រះមានភាពមមាញឹកបន្តកិច្ចដំណើរការនីតិវិធីលើករណី០០២ប្រឆាំងនឹងជនជាប់ចោទ នួន ជា, ខៀវ សំផន និង អៀង សារី ។ ការចាប់ផ្តើមថ្ងៃទីពីរ និងបញ្ចប់ គឺការផ្តល់សក្ខីកម្មរបស់សាក្សី យុន គីម អតីតគណៈឃុំសម្បូរ ។ បន្ទាប់មក គឺជាការសាកសួរសាក្សីបម្រុងនៅពេលរសៀល ។ ទោះជាយ៉ាងណាក៏ដោយ ជនជាប់ចោទ នួន ជា ក៏បានបង្កើតនូវការភ្ញាក់ផ្អើលមួយនៅពេលរសៀល នៅពេលដែលគាត់បានធ្វើសំណើថ្លែងទៅតុលាការមួយដែលមិនមាននរណាបានរំពឹងទុកមុន ។ នៅក្នុងដំណើរការនីតិវិធីថ្ងៃនេះ ភាគីស្ទើរតែទាំងអស់ ឬមេធាវី បានធ្វើការជំទាស់ ឬចូលរួមត្រួតពិនិត្យលើសាក្សីនៅអង្គជំនុំជម្រះ ។

អ្នកភូមិជាង៤៨០នាក់ បានចូលរួមក្នុងសវនាការ ។ អ្នកទាំងនោះរួមមាន បុរស នារី ចាស់ ក្មេង និងព្រះសង្ឃ ដែលក្នុងចំណោមនោះ៣៣០នាក់ ធ្វើដំណើរមកពីស្រុកមុខកំពូល ខេត្តកណ្តាល ហើយ១១០នាក់ទៀតមកពីខេត្តតាកែវ ។ ថ្វីបើតាមធម្មតាអ្នកមកទស្សនាចូលរួមសវនាការតែនៅពេលព្រឹក ឬពេលថ្ងៃ តែអ្នកចូលរួមថ្ងៃពុធនេះ ហាក់ដូចជាតាមដានទៅលើដំណើរការនីតិវិធីយ៉ាងល្អ រហូតដល់ពេលរសៀល ។ ការពន្យារពេលចូលរួមសវនាការ គឺជាការល្អពីព្រោះ នួន ជា បានធ្វើសេចក្តីជូនដំណឹង ។ បន្ទាប់ពីពេលសម្រាកអាហារថ្ងៃត្រង់ រហូតដល់ពេលរសៀល នួន ជា ពុំដែលមានការថ្លែងទៅតុលាការដោយផ្ទាល់ខ្លួនឡើយ តាំងពីខែមេសា មកម្លេះ ។

សមាជិកទាំងអស់នៃអង្គជំនុំជម្រះ មានវត្តមានក្នុងដំណើរការនីតិវិធី លើកលែងតែ អៀង សារី និងសហមេធាវីអន្តរជាតិ ម៉ៃខល កាណាវ៉ាស ។ ថ្វីបើ អៀង សារី ត្រូវបានអនុញ្ញាតឲ្យចូលរួមនៅដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួន មន្ត្រីតុលាការបានប្រកាសថា លោក ម៉ៃខល កាណាវ៉ាស អវត្តមាន «ដោយគ្មានហេតុផល» ។ គាត់បានប្រាប់ផងដែរថា សាក្សី បម្រុង TCW 321 កំពុងនៅក្នុងបន្ទប់រង់ចាំបានត្រៀមខ្លួនរួចជាស្រេចដើម្បីផ្តល់សក្ខីកម្ម បន្ទាប់ពីសក្ខីកម្មរបស់លោក គីម បានបញ្ចប់ ។

បន្ទាប់មក លោកប្រធាន ណុន ក៏បានផ្តល់វេទិកាជូនទៅ សហព្រះរាជអាជ្ញាជាតិ វ៉ែន ពៅ ធ្វើការតាំងសំណួរទៅលើសាក្សី យុន គីម ។

### *ដើមបណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមត្រួតពិនិត្យទៅលើសាក្សី យុន គីម*

*លោក ពៅ ចាប់ផ្តើមសាកសួរសំណួរមួយចំនួនអំពី បញ្ហាទាក់ទិននឹងការចូលដំបូងរបស់ លោក គីម ជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា ។*

*លោក គីម បានបំភ្លឺថា ខ្លួនបានចូលជាមួយចលនាបដិវត្តន៍កម្ពុជា នៅក្រោយពេលដែលខេត្តក្រចេះបានរំដោះ ។ សួរថាមូលហេតុអ្វីបានគាត់សម្រេចចិត្តចូលចលនាបដិវត្តន៍បន្ទាប់ពីខេត្តក្រចេះបានរំដោះ? លោក គីម ឆ្លើយថា «បើសិនណាខ្ញុំមិនបានចូលជាមួយចលនាទេ ខ្ញុំអាចនឹងត្រូវមានគ្រោះថ្នាក់... ពីព្រោះចលនានោះមានលក្ខណៈសកម្មដែរបានខ្ញុំសម្រេចចិត្តចូលរួម... ម្យ៉ាងដើម្បីការពារខ្លួនខ្ញុំផង និងការពារប្រជាជនផង» ។*

*លោក ពៅ សួរអំពីការប្រជុំនៅឆ្នាំ១៩៧៣ជាមួយ នួន ជា ដែលលោក គីម បាននិយាយនៅអំឡុងពេលផ្តល់សក្ខីកម្មលើកមុន ។ លោក គីម បានពន្យល់ថា នៅពេលដែល នួន ជា មកឃុំដារនៅឆ្នាំ១៩៧៣ ទិសដៅសំខាន់របស់គាត់ គឺបង្រៀនប្រធានឃុំ អំពីថាតើត្រូវធ្វើយ៉ាងណាដើម្បីបង្កើតក្រុមប្រវាស់ដៃ ។*

*លោក គីម និយាយថា នួន ជា មកម្នាក់ឯង គឺគ្មានវត្តមានមេដឹកនាំបក្សកុម្មុនីស្តកម្ពុជាផ្សេងឡើយ ។ ថ្វីបើលោក គីម មិនដឹងពីតួនាទីជាក់លាក់របស់ នួន ជា នៅក្នុងបក្សកុម្មុយនីស្តកម្ពុជាក៏ដោយ ក៏គាត់បាននិយាយថា គាត់ក៏បានដឹងថា នួន ជា ក៏ជាផ្នែកមួយនៃគណៈមជ្ឈិម ឬជាអ្នកដឹកនាំកំពូលរបស់បក្សដែរ ។*

*នួន ជា ដែលតែងតែពាក់វ៉ែនតាខ្មៅ នៅពេលកិច្ចដំណើរការនីតិវិធីសវនាការ បានដោះវ៉ែនតាចេញទៅកាន់សាធារណៈជនដែលកម្រឃើញមុខមាត់ពិតរបស់អតីតមេដឹកនាំបក្សកុម្មុនីស្តកម្ពុជា ។ គាត់បានសម្លឹងមើលទៅតុរបស់គាត់ ដោយគ្មានសម្លឹងទៅអ្នកណាម្នាក់សោះ ហើយបិទបបូរមាត់ឡើងស្មើ ។*

*លោក ពៅ បន្តកិច្ចដំណើរការនីតិវិធីដោយសួរទៅ លោក គីម អោយពន្យល់ពីភាពខុសគ្នារវាងសហករណ៍ និងសហគមន៍ ។ លោក គីម បានឆ្លើយថា «សហករណ៍មានន័យថាអ្វីៗដែលយើងធ្វើ ការរួមគ្នា តែយើងចែកផលប្រយោជន៍គ្នា ។ ឯសហគមន៍យើងដាក់រួម ធ្វើរួមគ្នា ហូបរួមគ្នា ប៉ុន្តែ គ្មានការចែកប្រយោជន៍ឡើយ» ។*

*ចំពោះឃ្លាមួយនៅក្នុងចម្លើយរបស់ លោក គីម ក្នុងបទសម្ភាសនៅការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) ដែលគាត់បញ្ជាក់ថា «បន្ទាប់ពីសហករណ៍ពីរបានបង្កើតឡើង ពួកគេគ្មានបាននិយាយពីឃុំទៀតទេ» លោក ពៅ បានសួរទៅកាន់សាក្សីថា «នៅពេលនោះតើនៅមានមេឃុំ ឬគណៈឃុំ? ឬក៏លោកកាន់តំណែងពីរ គឺមេឃុំផង និងប្រធានសហករណ៍ផង?» ។*

លោក គីម ឆ្លើយថា «មេឃុំហ្នឹងមានតួនាទីជាប្រធានសហករណ៍តែម្តង ។ វាគ្មានមេឃុំថ្មីទេ មានតែប្រធានសហករណ៍មួយប៉ុណ្ណោះ ហើយមេភូមិក៏ទទួលខុសត្រូវតាមមុខព្រួញនីមួយៗផងដែរ» ។

លោក ពៅ សួរបន្ត «តើមានគណៈសហករណ៍ដែរឬទេ?» ។ លោក គីម ឆ្លើយថា «នៅពេលដែលឃុំបានក្លាយជាសហករណ៍ គណៈឃុំក៏បានក្លាយជាគណៈសហករណ៍» ។

លោក គីម បានជម្រាបទៅតុលាការថា គាត់មានតួនាទីជាមេឃុំនៅឃុំវត្តស្លនៈ និងឃុំសម្បូរ នៅចន្លោះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៧១ និងខែកុម្ភៈ ឆ្នាំ១៩៧៧ ។ គាត់បានប្រាប់ថា ក្នុងឃុំវត្តស្លនៈ មានតែសហករណ៍មួយប៉ុណ្ណោះដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ ។ នៅឃុំសម្បូរវិញ មានសហករណ៍ ពីរដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ ពីព្រោះឃុំសម្បូរធំជាង ។

## សាក្សី យុន គីម ពិភាក្សាពីវគ្គបណ្តុះបណ្តាលផ្នែកសីលធម៌ និងការអនុញ្ញាតឲ្យធ្វើដំណើរ

លោក ពៅ រំឭកទៅការផ្តល់សក្ខីកម្មមុនរបស់លោក គីម ចំពោះបញ្ហាអសីលធម៌ចំពោះនារី ។ បន្ទាប់មកលោក ពៅ សួរថា តើនេះគឺជារឿងធម្មតានៅសហករណ៍របស់គាត់ទេ? លោក គីម ឆ្លើយថា «នៅសហករណ៍របស់ខ្ញុំ ពាក់ព័ន្ធនឹងរឿងសីលធម៌ ខ្ញុំមិនដឹងថាមានក្មេងៗប្រព្រឹត្តអំពើទាំងនេះទេ ។ មានយុវជនខ្លះ ដែលបានប្រព្រឹត្តអំពើអស់ទាំងនេះ ប៉ុន្តែពួកគេមិនត្រូវបានចាប់ខ្លួនឡើយ ពួកគេគ្រាន់តែត្រូវបញ្ជូនឲ្យទៅរៀនសូត្រ» ។

លោក ពៅ សួរទៀតថា «តើលោកដែលធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាល លើផ្នែកសីលធម៌នេះដែរឬអត់?» លោក គីម ឆ្លើយថា ធ្លាប់ «ពីព្រោះបញ្ហានេះវាសំខាន់ណាស់ ។ វាប៉ះពាល់ដល់អាយុជីវិត ព្រោះប្រសិនបើមានការបំពាន វាអាចនឹងជាបញ្ហាមួយដែលប៉ះពាល់ដល់គោលនយោបាយរបស់បក្ស» ។

បន្ទាប់មក លោក ពៅ សួរថា «ចុះលោកមានបានសុំការអនុញ្ញាតក្នុងការធ្វើដំណើរដែរ ឬទេ?» លោក គីម ឆ្លើយថា «ចំពោះការធ្វើដំណើរដែលចាំបាច់… ត្រូវតែមានលិខិតចេញឲ្យដោយស្រុក ។» លោក គីម ក៏មិនដែលនឹកឃើញនឹងរៀបចំទៅណាមកណាឡើយ ទោះបីជាដោយសារតែគាត់មមាញឹកនឹងការងារជាមួយនឹងតួនាទីរបស់គាត់ជាគណៈឃុំក៏ដោយ ។ «ខ្ញុំនឹកឪពុកម្តាយខ្ញុំដែលនៅស្រុកក្រូចឆ្មារ» ។ គាត់បន្ថែមទៀតថា«ប៉ុន្តែខ្ញុំមិនដែលសុំការអនុញ្ញាតទៅលេងគាត់សោះ ។ វាកម្រនឹងមានមនុស្សណាម្នាក់មកសុំការអនុញ្ញាតដើម្បីទៅណា ។ មុនឆ្នាំ១៩៧៥ ប្រជាជនអាចសុំការអនុញ្ញាតទៅលេងឪពុកម្តាយ ប៉ុន្តែបន្ទាប់ពីឆ្នាំ១៩៧៥ វាគ្មានករណីនេះទៀតសោះ… នេះមិនមែនសំដៅសម្រាប់តែប្រជាពលរដ្ឋធម្មតាទេ តែវាក៏កើតមានចំពោះថ្នាក់ដឹកនាំផងដែរ ។»

## ការយល់ដឹងរបស់សាក្សី យុន គីម លើថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាក្រៅពី នួន ជា

ការយល់ដឹងដែលលោក គីម បានបញ្ជាក់ពីការស្គាល់ច្បាស់រួចមកហើយលើ នួន ជា ដូច្នេះ លោក ពៅ បានបន្តស៊ើបសួរពីការយល់ដឹងពីថ្នាក់ដឹកនាំបក្សដទៃទៀត ។

«តើលោកដឹងពីតួនាទីថ្នាក់ដឹកនាំកំពូលរបស់បក្សដែរឬទេ?» សួរដោយលោក ពៅ ។ លោក គីម ឆ្លើយថា «ខ្ញុំដឹងថា ប៉ុល ពត គឺជាលេខាបក្ស» ។

លោក ពៅ បន្ត «ចុះចំពោះលោក ខៀវ សំផន វិញបន្ទាប់ពីឆ្នាំ១៩៧៥?» លោក គីម និយាយថា «លោក ខៀវ សំផន គឺខ្ញុំធ្លាប់បានឮដែរថា គាត់ជាប្រមុខរដ្ឋនៃបក្សកុម្មុយនីស្តកម្ពុជា តែខ្ញុំមិនបានចាំច្បាស់ទេកាលហ្នឹង ។»

លោក គីម តបថា ចំពោះ អៀង សារី វិញ «ខ្ញុំបានដឹងថា លោក អៀង សារី ជារដ្ឋមន្ត្រីការបរទេស ។»

## សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ វ៉ែន ពៅ សន្និដ្ឋានការសួររបស់គាត់ទៅនឹងសាក្សី យុន គីម បន្ទាប់ពីសាកសួរពីសិទ្ធិអំណាចក្នុងការចាប់មនុស្ស

លោក ពៅ បានសួរថា «នៅតំបន់៥០៥ តើលោកដឹងថា យោធាមានសិទ្ធិសម្រេចចាប់មនុស្ស ឬក៏អ្នកណាដែលគេចោទថាជាខ្មាំងដែរឬទេ?»

លោក គីម ពន្យល់ថា «យោធាគ្មានតួនាទីចាប់ទេ វាគឺជាតួនាទីរបស់សន្តិសុខក្នុងការចាប់ខ្លួនមនុស្ស» ។ គាត់បានបន្តទៀតថា «យោធាគ្មានសិទ្ធិអំណាចធ្វើដូច្នេះទេ ពួកគេត្រូវវាយខ្មាំងដែលលបនៅតាមព្រំដែន នៅពេលដល់ពេលចាំបាច់ សូមអស់មតិ ។»

លោក ពៅ បានបញ្ចប់ការសួរនាំរបស់គាត់ ហើយបានប្រគល់វេទិកាជូនទៅសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ។

## សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត សាកសួរទៅកាន់សាក្សី យុន គីម ពីស្ថានភាពរស់នៅជាសហគមន៍

លោកស្រី ហ្វត បានជម្រាបថា គាត់មានត្រឹមតែ២-៣សំណួរប៉ុណ្ណោះ ហើយសូមអរគុណដល់លោក គីម សម្រាប់ការផ្តល់នូវព័ត៌មានជាច្រើនមកកាន់តុលាការ ។

ទាក់ទងនឹងស្ថានភាពរស់នៅរបស់ប្រជាជន ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ លោកស្រី ហ្វត សួរថា តើលោកធ្លាប់ឮពីស្ថានភាពរស់នៅដ៏លំបាកនៅសហករណ៍ដទៃទៀត ក្នុងពេលប្រជុំប្រចាំសប្តាហ៍

ជាមួយនឹងឃុំផ្សេងទៀត ។ លោក គីម ឆ្លើយថា «ខ្ញុំក្តាប់មិនបានទេពីបញ្ហានេះនៅសហករណ៍ផ្សេង» ប៉ុន្តែគាត់បានជម្រាបទៅតុលាការម្តងទៀតថា ប្រជាជនរបស់គាត់ហូបបាយ ។

លោកស្រី ហុត រៀបសំណួរម្តងទៀតថា «តើលោកធ្លាប់បានឮពីប្រធានសហករណ៍ដទៃទៀតនិយាយពីបញ្ហាអាហារដែរឬទេ?» ។ លោក គីម ឆ្លើយថា «ក្នុងអំឡុងពេលប្រជុំពុំមានរបាយការណ៍ណាដែលថាមានកង្វះខាតអាហារនៅសហករណ៍ផ្សេងទេ ។ ប៉ុន្តែដូចខ្ញុំបាននិយាយហើយ នៅសហករណ៍ផ្សេងទៀតប្រជាជនហូបបបរមិនមែនហូបបាយទេ ។»

លោកស្រី ហុត បន្តសំណួរថា «តើលោកធ្លាប់ឮពីស្ថានភាពការងារដ៏ធ្ងន់ធ្ងរនៅសហករណ៍ដទៃទៀតដែរឬទេ?» ។

«បាទ» លោក គីម ឆ្លើយតប «ខ្ញុំធ្លាប់ឮដែរពីរឿងនេះនៅក្នុងឃុំវឌ្ឍនៈ បន្ទាប់ពីខ្ញុំចាកចេញខ្ញុំក៏ទៅលេងម្តងម្កាល់ដែរ ។ ប្រជាជនបានប្រាប់ថា ក្រុមមុខព្រួញរបស់គេទទួលការរិតត្បិតណាស់ ។ ប្រជាជនត្រូវក្រោកតាំងពីម៉ោង៣ព្រឹក ហើយក្មេងៗដេកតាមភ្លឺស្រែ ។ អ្នកខ្លះត្រូវបានព្យាយាមបង្ខំឲ្យធ្វើការធ្ងន់ៗជាងមុន ។ នេះខ្ញុំគ្រាន់តែលើកជាឧទាហរណ៍» គាត់បន្ថែម ។

លោកស្រីបានសួរបន្ត «តើលោកធ្លាប់បានដឹងពីរឿងមនុស្សដែលធ្លាក់ខ្លួនឈឺដែរឬទេ?» ។ «ក្នុងស្រុកសម្បូរ យើងពុំដែលមានជួបពីបញ្ហាទាំងនេះទេ» លោក គីម ឆ្លើយតប ។ «ប្រជាជនឈឺមិនមែនដោយសារកម្រិតនៃអាហារទេ ប៉ុន្តែគឺដោយសាររោគផ្សេងៗ ដោយឡែក គឺជម្ងឺគ្រុនចាញ់… ខ្លួនខ្ញុំផ្ទាល់ ក៏ធ្លាប់បានសម្រាកនៅមន្ទីរពេទ្យហ្នឹងដែរ ដោយសារតែជម្ងឺគ្រុនចាញ់នេះ ។»

លោកស្រី ហុត បានបន្តការសួរទៅមុខទៀត ។ បន្ទាប់ពីរំឮកឡើងវិញចំពោះគាត់ថា គាត់ធ្លាប់បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួនរបស់កម្មាភិបាលថា បន្ទាប់ពីមានការអញ្ជើញឲ្យចូលរួមក្នុងការប្រជុំរបស់បក្ស តើគាត់បានពិភាក្សា ឬធ្លាប់ឮការពិភាក្សាអំពីហេតុផលក្នុងការចាប់ខ្លួនទាំងនេះដែរទេ?

លោក គីម និយាយថា «ខ្ញុំខ្លួនឯងផ្ទាល់ មិនដែលបានពិភាក្សាគ្នាពីការចាប់ខ្លួននេះជាមួយអ្នកណាទេ ។» «តាមការពិតមិត្តភក្តិខ្ញុំខ្លះក៏បានបាត់ខ្លួនដែរ… យើងមិនដែលបង្ហាញពីអារម្មណ៍ពិតរបស់យើងថាប្រហែលនៅថ្ងៃក្រោយគឺជាវេនរបស់យើងម្តងហ្នឹងឯង ។»

«ហេតុអ្វី បានជាលោកមិននិយាយពីបញ្ហានេះ?» សួរដោយលោកស្រី ហុត ។

លោក គីម ពន្យល់ថា «ទីមួយ យើងមានការបារម្ភ» ។ ឧទាហរណ៍ ប្រសិនបើឈ្មោះ «ក» ត្រូវចាប់ខ្លួនទៅ រួចយើងនិយាយពីរឿងចាប់ខ្លួនគាត់ និងហេតុផលពីការចាប់ខ្លួនគាត់ ពេលនោះយើងនឹងចាប់ផ្តើមលែងទុកចិត្តលើអ្នកណាម្នាក់ថែមទៀត ។ ប្រសិនបើមានការរាយការណ៍ណានិយាយថា

យើងបាននិយាយពីរឿងនេះ វានាំឲ្យយើងនឹងប្រឈមមុខនឹងគ្រោះថ្នាក់ដល់ខ្លួន។ ដូច្នេះ ពួកយើងមិនដែលនិយាយពីរឿងនោះឡើយ ។»

បន្ទាប់មក លោកស្រី ហុត បានសួរពីរបៀបនៃការរៀបការ ។ «ខ្ញុំមិនបានដឹងច្បាស់ពីរឿងរៀបការទេ» ឆ្លើយតបដោយលោក គីម ហើយពន្យល់ថា ខ្លួនធ្លាប់តែបានឮពីការរៀបចំការរៀបការនេះ នៅពេលដែលគាត់បានចូលរួមការប្រជុំប៉ុណ្ណោះ ។ គាត់ជឿជាក់ថា របៀបចាត់ចែងនេះគ្រាន់តែដើម្បីសន្សំពេលវេលា និងទ្រព្យធន ។

យ៉ាងណាមិញលោក គីម បានបន្ថែមដោយញញឹមថា «ពេលខ្លះ ខ្ញុំក៏ជាអ្នករៀបចំពិធីនេះដែរ ច្រើនណាស់ក៏មានការរៀបការចំនួនពីរគូដែរ ។ជួនកាលយើងកាប់គោមួយដើម្បីធ្វើពិធីនេះ ។»

លោកស្រី ហុត បានបញ្ចប់ការសួរនាំរបស់លោកស្រីចំពោះលោក គីម ។

## ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ធ្វើការសាកសួរទៅសាក្សី

មុននឹងផ្តល់តួនាទីទៅមេធាវីការពារក្តីចាប់ផ្តើមនូវការឆ្លងកាត់ការសាកសួរ លោកប្រធាន ណុន បានសួរទៅសមាជិកនៃអង្គចៅក្រមថា តើចង់ដាក់សំណួរទៅសាក្សីបន្ថែមដែរឬទេ។ ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន ជម្រាបទៅតុលាការថា លោកមាន២-៣សំណួរសម្រាប់សួរទៅសាក្សី ។

ចៅក្រម ឡាវ៉ែន បន្តដំណើរការសាកសួរទៅលោក គីម លើសំណួរមួយចំនួនដែលទាក់ទងនឹងទីតាំងភូមិសាស្ត្រនៃឃុំសម្បូរ បន្ទាប់ជាប្រធានសហករណ៍ស្រែខ្ទឿន និងមន្ទីរ«ប-៣» ។

បន្ទាប់មកលោក គីម បានប្រាប់ថា មានប្រាំបីឃុំដែលនៅពេលនោះលោកបែងចែកជាសហករណ៍ពីរគឺ សហករណ៍សម្បូរ និងសហករណ៍ស្រែខ្ទឿន។ ចៅក្រមសួរទៅលោក គីម ថា ស្រែខ្ទឿនហ្នឹងវាត្រូវបានស្គាល់ថា ជាកែងប្រាសាទមែនទេ ។

«ទេ» លោក គីម ឆ្លើយតប «វាគ្រាន់តែជាផ្នែកមួយនៃសហករណ៍ស្រែខ្ទឿនប៉ុណ្ណោះ ។ វាជាភូមិមួយក្នុងចំណោមភូមិបួនដែលនៅក្នុងសហករណ៍ស្រែខ្ទឿន ។» គាត់បន្ថែមថា ភូមិកែងប្រាសាទស្ថិតនៅកន្លែងមន្ទីរសន្តិសុខគោកក្តួច ។ យ៉ាងណាមិញ លោក គីម បានពន្យល់ថា មន្ទីរសន្តិសុខគោកក្តួច មិនស្ថិតក្រោមការគ្រប់គ្រងរបស់សហករណ៍ស្រែខ្ទឿនឡើយ ទោះជាការពិតវាស្ថិតនៅលើទឹកដីនោះក៏ដោយ ។ គាត់ក៏បាននិយាយថា មន្ទីរសន្តិសុខស្ថិតនៅក្រោមការត្រួតត្រារបស់ស្រុក ។

«អ្នកណាជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខគោកក្តួច?» សួរដោយចៅក្រម ឡាវ៉ែន។ «ខ្ញុំក្តាប់មិនបានទេថាអ្នកណាជាប្រធាន... តែពីមុនវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អ៊ុង សាម៉ុន... ប៉ុន្តែ គិន

ជន មកជំនួសតំណែងគាត់… សារឿន ជាអ្នកប្រចាំការនៅទីនោះ… បន្ទាប់មកទៀត បេ ម៉េង អាន ត្រូវបានធ្វើជាលេខា» ឆ្លើយដោយលោក គីម ។

ចៅក្រមឡាវ៉ៃន៍សួរ «តើអ្នកដែលជាប្រធានរបស់ ប-៣ ក៏ជាប្រធាននៃមន្ទីរសន្តិសុខគោកក្ដួចដែរមែនទេ?» «ប-៣ និងគោកក្ដួច ស្ថិតនៅកន្លែងផ្សេងគ្នា» ឆ្លើយដោយលោក គីម ។ «គោកក្ដួចនេះ ជាមន្ទីរសន្តិសុខរបស់ស្រុកសម្បូរ ។ ប-៣ ដែលកាលមុនប្តូរជាការដ្ឋានយុវជន យុវនារីនេះ គឺជាកន្លែងសន្តិសុខដែលគេប្រមូលកម្មាភិបាលទៅដាក់នៅទីនោះ ។ គាត់បានបន្ថែមថា ដូច្នេះកន្លែងមួយសម្រាប់សហករណ៍ (ស្រែខ្មឿន) ហើយមួយទៀតជាកន្លែងរបស់ស្រុក ។»

ចៅក្រម ឡាវ៉ៃន៍ សួរថា «តើលោកបន្តតំណែងពី សារឿន មែនទេ?» ។ លោក គីម កែតម្រូវចៅក្រមវិញថា «មានមនុស្សផ្សេងទៀតឈ្មោះ សារឿន ដែលជាអ្នកគ្រប់គ្រងនៅប-៣ ។»

លោក គីម ពន្យល់ថា នៅពេលសួរពីមនុស្សម្នាក់ឈ្មោះ ពេន «ពេន ជាអនុប្រធាននៅសហករណ៍ស្រែខ្មឿន ហើយគាត់ក៏ត្រូវបានតែងតាំងឲ្យជួយខ្ញុំនៅពេលដែលខ្ញុំជាប្រធាននៅ ប-៣ ។»

«តើលោកអាចប្រាប់យើងបានទេថា នៅកាលៈទេសៈណាដែល ពេន ត្រូវស្លាប់នោះ?» ស្នើសួរដោយចៅក្រម ឡាវ៉ៃន៍ ។

«នៅពេលដែល ពេន មកធ្វើជាប្រធានសហករណ៍នៅវគ្គនេះនេះ គាត់នៅទីនេះរហូតដល់ថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩» ពន្យល់ដោយលោកសាក្សី ។ «បន្ទាប់មកគាត់ត្រឡប់មកភូមិរបស់គាត់វិញ ហើយប្រជាជនបានវាយគាត់ស្លាប់… វាមានពាក្យចចាមអារាមថា ដោយសារគំនុំខ្លះ និងដោយសារគាត់ទុកសម្ភារៈមួយចំនួនរបស់អ្នកដែលត្រូវបានសម្លាប់ ។ ដូច្នេះ គាត់ត្រូវបានគេវាយឲ្យស្លាប់ពេលដែលគាត់ទៅយកសម្ភារៈទាំងនោះ ។»

«លោកអាចប្រាប់ខ្ញុំបានទេនៅពេលដែលលោកទៅដល់ ប-៣ តើអ្នកណាខ្លះដែលនៅ ប-៣ ហ្នឹង? តើអ្នកទាំងនោះមាននៅប-៣ទៀតទេ?» សួរដោយចៅក្រម ឡាវ៉ៃន៍ ។

លោក គីម ពន្យល់ថា ប-៣នោះជាកន្លែងឃុំឃាំងគណៈសហករណ៍ និងថ្នាក់ស្រុក ដែលត្រូវចាត់ទុកថាជាខ្មាំង ។ វាមិនមែនចាត់ទុកថាជាកន្លែងមន្ទីរសន្តិសុខអីនោះទេ តែវាប្រៀបដូចជាមន្ទីរកែប្រែទៅវិញ ។ លោក គីម និយាយថា «អ្នកដែលត្រូវបានឃុំទាំងនោះ សុទ្ធតែជាអ្នកដែលមិនបានប្រព្រឹត្តិអ្វីខុសធ្ងន់ធ្ងរឡើយ ។ ពួកគេមក គឺដើម្បីរៀនសូត្រ ។» យ៉ាងណាក៏ដោយ ពេលដែលប-៣ នេះត្រូវបានបោសសម្អាត លោក គីម បានទទួលស្គាល់ថា លោកពិតជាមិនបានដឹងថា អ្នកជាប់ឃុំឃាំងត្រូវបានគេយកទៅណាឡើយ ។

លោក គីម បានបន្តថា បន្ទាប់ពីការដែលយកចេញនូវកម្មាភិបាលថ្នាក់លើដែលបានឃុំខ្លួនក្រុមយុវជនយុវនារី ដែលស្ថិតក្រោមការគ្រប់គ្រងរបស់លោក សារិន មកដល់ប-៣ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨។ យ៉ាងណាមិញ លោក គីម បានពន្យល់ថា ដោយសារសារិនមានសាវតាធ្លាប់ជាយោធា និងប្រើប្រាស់អំណាចខ្លាំងពេកទើបបានជាលោក គីម បានតែងតាំងជំនួសគាត់ជាប្រធាន ប-៣ វិញ។

លោក គីម បន្ថែមទៀតថា «សរុបទាំងអស់ មានយុវជន យុវនារីប្រហែល៧០០នាក់» ប៉ុន្តែមាន២០០នាក់ថ្មី ដែលមកដល់បន្ទាប់ពីគាត់បានតែងតាំងជាប្រធាននៅប-៣ បានស្នាក់នៅមន្ទីរត្រឹមតែ២ខែប៉ុណ្ណោះមុនពេលគេដកយកទៅ។

ចៅក្រម ឡាវីន័ សួរថា «តើយុវជន យុវនារីទាំងនេះ មកពីខាងណាដែរ?» លោក គីម និយាយថា អ្នកមកថ្មី២០០នាក់នោះ មកពីភូមិត្រមូង ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។ «ខ្ញុំមិនដឹងថាហេតុអ្វីបានជាពួកគេត្រូវផ្ទេរមកកន្លែងខ្ញុំទេ» គាត់បានបន្ថែម «ប៉ុន្តែខ្ញុំដឹងថាភូមិត្រមូងនេះ នៅជិតនឹងព្រំដែនវៀតណាម។»

ចៅក្រម ឡាវីន័ ក៏អានទៅលើចម្លើយដែលលោក គីម បានឆ្លើយទៅកាន់ ក.ស.ច.ស «មនុស្សទាំងនោះត្រូវបានសង្ស័យថា ជាប់ពាក់ព័ន្ធជាមួយវៀតណាម។»

«ខ្ញុំគ្រាន់តែដឹងថា ពួកគេរស់នៅជិតព្រំប្រទល់ខ្មែរ-វៀតណាម» ពន្យល់ដោយលោក គីម។ «ខ្ញុំគ្រាន់តែសន្មតថា ពួកគេមានជាប់ខ្សែជាបក្សពួកជាមួយវៀតណាមខ្លះ។»

បន្តមកសំណួររបស់ចៅក្រម ឡាវីន័ វិញ «តើប-៣ស្ថិតនៅក្នុងភូមិដែលហៅថា គេកត់ (ស៊ីក) ក្នុងស្រុកសម្បូរហ្នឹងមែនទេ?»

លោក គីម ឆ្លើយថា «វាស្ថិតនៅជិតភូមិស្រែវង់។» លោក គីម ពន្យល់ថា «វាស្ថិតនៅក្នុងស្រុកក្រចេះមួយចំហៀង និងនៅស្រុកសំបូរមួយចំហៀង។» «អញ្ចឹងវាពាក់កណ្តាលម្នាក់នៃស្រុកទាំងពីរនេះ។»

«តើមានជនជាតិភាគតិចនៅក្នុងឃុំសម្បូរដែរឬទេ?» សួរដោយចៅក្រម ឡាវីន័។ «នៅក្នុងភូមិសម្បូរមានតែជនជាតិខ្មែរប៉ុណ្ណោះ» លោក គីម ថា «ប៉ុន្តែដល់ក្នុងស្រុកសំបូរមានជនជាតិភាគតិចច្រើន។»

## ***សហមេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា លោក អេនឌ្រូ អ៊ីនូហ្សុី លើកឡើងអំពីបញ្ហានីតិវិធី ដែលចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ប្រើប្រាស់ទាក់ទងនឹងសេចក្តីថ្លែងរបស់សាក្សី***

*នៅពេលដែលចៅក្រម ឡាវែន៍ បន្តការអានទៅលោក គីម ដោយដកស្រង់ពីឯកសារដែលមានក្នុងការថ្លែងសម្ងាត់របស់សាក្សី ស្រាប់តែលោក អេនឌ្រូ អ៊ីនូហ្សុី សហមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានក្រោកឡើងចំពោះមុខតុលាការ ។*

*«ខ្ញុំសូមឲ្យបំភ្លឺច្បាស់» ប្រកាសដោយលោក អ៊ីនូហ្សុី ។ «តើសាក្សីរូបនេះ ជាសាក្សីដែលត្រូវកំណត់យកមកផ្តល់សក្ខីកម្មឬ? » តាមដែលខ្ញុំយល់ វិធានដែលមានចែងក្នុងអង្គជំនុំជម្រះនេះថា ការថ្លែងរបស់សាក្សីអាចលើកឡើង ប្រសិនបើសាក្សីមិនបានមកផ្តល់សក្ខីកម្មប៉ុណ្ណោះ ។»*

*ចៅក្រម ឡាវែន៍ បានឆ្លើយថា «ខ្ញុំខ្លាចក្រែងថា ការស្នើសុំនេះត្រូវតែមានការស្រាវជ្រាវសិន ពីព្រោះខ្ញុំមិនប្រាកដថា តើសាក្សីរូបនេះមាននៅក្នុងបញ្ជីនោះទេ» ដោយអូសក្រដាសមុនគាត់ ។*

*ជំនួយការសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ យ៉ាងណាមិញបានថ្លែងទៅតុលាការ និងជម្រាបទៅកាន់ចៅក្រម ឡាវែន៍ ថា សាក្សីរូបនេះមិនត្រូវបានកោះអញ្ជើញមកធ្វើសក្ខីកម្មទេ ។*

*ជាមួយនឹងបញ្ហាដែលបានបញ្ចប់ហើយ ចៅក្រម ឡាវែន៍ បន្តស្រង់សម្តីទៅតាមអ្វីដែលទាក់ទងនឹងសាក្សីដែលជាអ្នកធ្វើការនៅឃុំស្រែខឿន «នៅចន្លោះខែមិថុនា និងខែកក្កដា ឆ្នាំ១៩៧៦ គេបានដកខ្ញុំទៅធ្វើការនៅសហករណ៍ក្នុងភូមិស្រែខឿន ។ គេឲ្យយើងធ្វើការទាំងថ្ងៃទាំងយប់... អត់មានពេលទំនេរឡើយ ។ នៅពេលនោះ គឺមិនទាន់មានម៉ាស៊ីនសម្រាប់កិនអង្ករទេ គេប្រើកម្លាំងមនុស្ស... ការហូបចុកមិនគ្រប់គ្រាន់ទេ គេហូបរួមគ្នា ។ ពេលខ្លះបានបាយមួយពេល ឬបបរមួយពេលប៉ុណ្ណោះ អស់ហើយ ។ នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ មានប្រជាជនថ្មីមកចូលសហករណ៍ ដែលមកពីកន្លែងផ្សេងៗគ្នា ។ គេក្លាយជាចំនួនភាគច្រើន អ្នកខ្លះមកពីបូព៌ាត្រូវគេបញ្ជូនមកតំបន់៥០៥... ពេលគេមកដល់ គឺអត់មាននិយាយអ្វីទាំងអស់ ។ អ្នកខ្លះស្លាប់ដោយសារអត់ឃ្លាន... ខ្លះទៀតស្លាប់ដោយសារខ្វះខាតថ្នាំព្យាបាល ។»*

*«សាក្សី ចំពោះអ្វីដែលខ្ញុំបានអានចេញមកនេះ តើវាត្រឹមត្រូវទៅនឹងអ្វីដែលបានកើតឡើងដែរឬទេ? »*

*លោក គីម ឆ្លើយថា «តាមការបំភ្លឺរបស់សាក្សីនេះ វាមិនសូវជាត្រឹមត្រូវប៉ុន្មានទេ ។» បន្ទាប់ពីការឲ្យឧទាហរណ៍ នៃការពិតដែលវាមិនត្រឹមត្រូវចំពោះមនុស្សដែលនិយាយនៅក្នុងការថ្លែងនេះ លោក គីម បន្ថែមថា «ក្នុងការបំភ្លឺនេះ ម្តងទៀតវាពិតជាមិនច្បាស់លាស់ និងត្រឹមត្រូវទេ អញ្ចឹងខ្ញុំ*

មិនអាចទទួលសម្ដីរបស់គាត់បានទេ ពិសេសដោយសារតែខ្លួនខ្ញុំផ្ទាល់ជាអ្នកគ្រប់គ្រងនៅសហករណ៍ស្រែខឿននេះតែម្ដង ។»

បន្តសំណួរទៀតដោយចៅក្រម ឡាវ៉ែន «តើលោកមានសម្គាល់ឃើញមានវត្តមានរបស់ជនជាតិចាមនៅក្នុងសហករណ៍របស់លោកទេ?» លោក គីម ឆ្លើយថា «ខ្ញុំធ្លាប់បានឃើញគេជម្លៀសជនជាតិចាមទៅក្នុងឃុំវឌ្ឍនៈ ពេលដែលខ្ញុំធ្វើមេឃុំនៅទីនោះ ។ តែយ៉ាងណាក៏ពុំមានឃើញ បែងចែកជាមនុស្សប្រភេទណានោះទេ ។»

ចៅក្រម ឡាវ៉ែន បន្តដាក់ជូនឯកសារផ្សេងទៀតបង្ហាញដល់លោក គីម ។ ឯកសារនេះក៏មានរួមបញ្ចូលផងដែរនូវការបំភ្លឺរបស់សាក្សីដែលមិនបញ្ចេញឈ្មោះ ។ មុនពេលចាប់អាននូវឯកសារនោះ លោក អ៊ីនូហ្ស៊ី បានបន្ទាក់ទៅតុលាការម្ដងទៀតជាមួយនឹងសំណើដូចគ្នា ។

លោក លីសាក់ ក៏ធ្លាប់បាននិយាយទៅកាន់តុលាការ និងជម្រាបដល់អង្គជំនុំជម្រះកាលពីសប្ដាហ៍មុនថា «មេធាវីអន្តរជាតិ នួន ជា បានស្នើសុំចោទសួរសាក្សីមួយអំពីសេចក្ដីបំភ្លឺរបស់សាក្សីដែលមានឈ្មោះក្នុងបញ្ជីដែលត្រូវកោះហៅមកផ្ដល់សក្ខីកម្ម ។ គាត់បានទទួលការអនុញ្ញាត ។»

បន្ទាប់ពីមានយោបល់បន្ថែមពីលោក អ៊ីនូហ្ស៊ី និងសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន ឈ្មោះ អាកទូរ វ៉ែកកែន ចៅក្រម ឡាវ៉ែន បានជម្រាបទៅអង្គជំនុំជម្រះថា ដែនកំណត់នៃនីតិវិធី ដែលអនុវត្តចំពោះគ្រប់ភាគីក្នុងអង្គជំនុំជម្រះ «មិនអាចយកមកអនុវត្តជាមួយចៅក្រមបានទេ ។» គាត់ក៏បន្តការអានការបំភ្លឺរបស់សាក្សីដែលមិនបញ្ចេញឈ្មោះថា ជនជាតិចាមដែលបានបញ្ជូនទៅរស់នៅក្នុងភូមិសម្បូរ ស្រុកសម្បូរ ខេត្តក្រចេះ «យើងចាប់ផ្ដើមធ្វើការនៅម៉ោង ៣ព្រឹករហូតដល់ម៉ោង១១ថ្ងៃត្រង់ ហើយពីម៉ោង១ថ្ងៃដល់ម៉ោង៥ល្ងាច និងពីម៉ោង៦ល្ងាចដល់ម៉ោង៩យប់ ។»

«តើអ្វីដែលមាននៅក្នុងការស្រាយបំភ្លឺនេះ វាសមស្របទៅនឹងការចងចាំរបស់លោកដែរឬទេ ឬក៏វាខុសពីការចងចាំរបស់លោក?» សួរដោយចៅក្រម ឡាវ៉ែន ។ លោក គីម ឆ្លើយថា លោកមិនបានដឹងពីបញ្ហាដែលមានខ្មែរអ៊ីស្លាមត្រូវបានជម្លៀសទៅឃុំសម្បូរនោះទេ ប៉ុន្តែបានពន្យល់ថា នៅពេលនោះក៏ពុំមានការបែងចែកក្រុមមនុស្សដែលរស់នៅក្នុងសំបូរដែរ ។ លោកក៏បាននិយាយដែរថា លោកពុំបានដឹងថា ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការច្រើនម៉ោងដូចនេះដែរ ។

មុននឹងបញ្ចប់ការសួរនាំ ចៅក្រម ឡាវ៉ែន ជម្រាបទៅលោក គីម ពីឯកសារផ្សេងទៀតដែលជាទូរលេខផ្ញើរទៅ បងនួន និងចុះហត្ថលេខាដោយ ឈុន ដែលមាននិយាយពីប្រជាជនចាមដែលរស់នៅភូមិភាគបូព៌ា ។ បន្ទាប់មកលោកប្រគល់តួនាទីទៅលោកប្រធាន ណុន ។

## ប្រធានអង្គជំនុំជម្រះសួរទៅកាន់សាក្សី

មុននឹងអនុញ្ញាតទៅដល់ក្រុមមេធាវីការពារក្តីដាក់សំណួររបស់ខ្លួន លោកប្រធាន និល ណុន ក៏មានសំណួរមួយចំនួនដើម្បីសួរទៅកាន់លោក គីម ដែរ ។

«តើលោកធ្លាប់បានទទួលឧបករណ៍ ឬក៏មធ្យោបាយផលិតកម្មណាមួយពីថ្នាក់លើដែរឬទេ?» សាក្សីបានពន្យល់ថា ក្រោយពីឆ្នាំ១៩៧៥ យើងសំបូរណាស់នូវមធ្យោបាយផលិតកម្ម ។ ចប និងនង្គ័លគឺមានគ្រប់ដៃ ។ ដាងដែកធ្វើកាបិត ។ យើងគ្រាន់តែសុំទៅថ្នាក់ស្រុកហ្នឹងជួយផ្តល់ដែកថែប ។

លោក ណុន បានសួរពីមធ្យោបាយផលិតកម្មមួយផ្សេងទៀត ដូចជាក្រណាត់សម្លៀកបំពាក់ជាដើម ។ «សម្លៀកបំពាក់ត្រូវបានយកមកឲ្យប្រជាជន ហើយប្រជាជនម្នាក់បានទទួលសម្លៀកបំពាក់ ២កំផ្លេ» ឆ្លើយដោយលោក គីម ។ «ក្រុមអ្នកកាត់ដេរ ទទួលរ៉ាប់រងខាងដេរខោអាវជូនប្រជាជនដែលនៅក្នុងសហករណ៍ ។ ហើយក៏មានក្រុមអ្នកត្បាញ ដែលមានមុខងារត្បាញក្រម៉ា ឬកន្ទេងបង់កសម្រាប់សហករណ៍ដែរ ។» យ៉ាងណាក៏ដោយលោក គីម បន្ថែមថា «វាកើតឡើងតែក្នុងឃុំប៉ុណ្ណោះ ។ ពេលដែលខ្ញុំមក ប-៣ របស់ទាំងនេះត្រូវបានផ្តល់ឲ្យដោយគណៈស្រុក ។»

## សាក្សី យុន គីម កែប្រែនូវរបាយការណ៍ផលិតកម្ម ដើម្បីទុកបាយផ្តល់ឲ្យប្រជាជន

លោកប្រធាន ណុន សួរថា «តើលោកមានធ្លាប់បានទទួលបញ្ជាពីថ្នាក់លើទាក់ទងនឹងផែនការផលិតស្រូវបីតោនក្នុងមួយហិចតាដែរឬទេ?» លោក គីម ឆ្លើយថា «យើងអនុវត្តគោលនយោបាយប្រកួតប្រជែងនៅឆ្នាំ១៩៧៦ ដែលជាដំណាក់កាលទីមួយ ។ វាជាការរួមចំណែកនៃសហករណ៍នីមួយៗ ដែលត្រូវផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតា ។ ខ្ញុំក៏បានរួមចំណែកជាមួយការប្រកួតប្រជែងនេះនឹងសហករណ៍ផ្សេងទៀតដែរ ។» លោក គីម បន្តទៀតថា «ឆ្នាំនោះ នៅស្រុកខេត្តក្រចេះទាំងមូលគឺឃុំខ្ញុំបានទទួលតំណែងលេខមួយ ។ ទោះបីជាយើងមិនអាចផលិតបានបីតោនក្នុងមួយហិចតា យើងក៏ផលិតបាន១៨៣ថាំង ។ ខ្ញុំរាយការណ៍ថា ស្រុកខ្ញុំផលិតបានត្រឹមតែ១១៣ថាំងទេ គឺលាក់ទុក៣តោនទេ ។ ការធ្វើដូចនេះ គឺដើម្បីទុកអង្ករខ្លះ ដូច្នេះប្រជាជនមិនចាំបាច់ហូបបបរទេ ។»

លោក គីម បាននិយាយថា ទោះបីជាយ៉ាងណាក៏ដោយក៏មានការខ្វះខាតអាហារនៅតាមតំបន់ខ្លះៗដែរ «ខ្ញុំសូមលើកឧទាហរណ៍មួយ» គាត់និយាយថា «ភូមិជ្រោយបន្ទាយ មានបញ្ហាការខ្វះខាតអាហារ ។ ខ្ញុំសម្គាល់ឃើញពីបញ្ហានេះ ហើយខ្ញុំក៏ធ្លាប់បានផ្តល់ដំឡូង ឬចេកទៅឲ្យអ្នកទាំងនោះដែរ ។ យើងមិនដឹងមូលហេតុយ៉ាងម៉េចទេ បានជាពួកគេគ្មានអាហារហូបគ្រប់គ្រាន់ ថ្វីបើយើងមានស្ថានភាពដីស្រែដូចគ្នា ។»

លោកប្រធាន ណុន បានបញ្ចប់ការសួរនាំរបស់គាត់ និងផ្អាកអង្គជំនុំជម្រះសិន ដើម្បីពិសារអាហារថ្ងៃត្រង់ ។

## អង្គជំនុំជម្រះចេញសេចក្តីសម្រេចលើញត្តិនៃវិធាន៨៧ របស់មេធាវីការពារក្តី នួន ជា

សហមេធាវីអន្តរជាតិការពារក្តី នួន ជា លោក អេនឌ្រូ អ៊ីនូហ្សី បានលើកបញ្ហាបឋម មុននឹងដាក់សំណួរទៅកាន់សាក្សី ។ បញ្ហាគឺទាក់ទងនឹងសំណើពីថ្ងៃមុនពេលដែលគាត់បានស្នើសុំការសម្រេចលើញត្តិនៃវិធាន៨៧របស់ក្រុមគាត់ បានដាក់ជូនទៅជាងមួយសប្តាហ៍ហើយ ។ លោក អ៊ីនូហ្សី សួរថា តើអង្គជំនុំជម្រះបានសម្រេចហើយឬនៅ ។

បន្ទាប់ពីពិភាក្សាជាមួយនឹងចៅក្រមផ្សេងទៀត លោកប្រធាន ណុន បានប្រកាសថា “អង្គជំនុំជម្រះនឹងមិនឆ្លើយតបទៅនឹងសំណើសុំរបស់លោកមេធាវីបានដាក់នោះទេ ពីព្រោះឯកសារដែលលោកបានដាក់នោះមិនមែនជាឯកសារភស្តុតាងថ្មីទេ ។ វាជាសេចក្តីសម្រេចដែលគួរតែដំណើរការនៅដំណាក់ការសហចៅក្រមស៊ើបអង្កេត ។” លោកបានបន្តប្រាប់ទៅលោក អ៊ីនូហ្សី ថា ឯកសាររបស់តុលាការទាំងនោះមិនអាចដាក់ជូនជាភស្តុតាងដើម្បីប្រើក្នុងតុលាការទេ ។ ដើម្បីបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ជាងនេះ លោកប្រធាន ណុន បានផ្តល់វេទិកាជូនទៅលោកចៅក្រម ឡាវ៉ឺន៍ ។

លោកចៅក្រម ឡាវ៉ឺន៍ និយាយថា “ខ្ញុំជឿថា អ្វីដែលលោកប្រធាននិយាយនេះគឺច្បាស់លាស់ហើយ ។ ជាការពិត អ្វីដែលយើងគួរតែចងចាំនោះ គឺសេចក្តីសម្រេចដែលលោកបានយោងនោះ វាមិនមែនជាភស្តុតាងទេ ហើយវាក៏មិនគោរពទៅតាមវិធាន៨៧នោះដែរ យ៉ាងណាមិញ វិធាន៨៧នេះ គឺអនុវត្តទៅលើការបង្ហាញភស្តុតាងថ្មី ។” ចៅក្រម ឡាវ៉ឺន៍ បានបន្ត “អង្គជំនុំជម្រះនឹងវាយតម្លៃថា តើសំណួរដែលផ្អែកទៅលើសេចក្តីសម្រេចដែលយោងនោះ ពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធ ហើយលោកប្រធានមានសិទ្ធិក្នុងការបញ្ចប់សួរសំណួរ ដែលមិនមានការពាក់ព័ន្ធ ។ ប៉ុន្តែលោកអាចយោងតាមឯកសារនោះបាន ពីព្រោះថា នេះជាកិច្ចនីតិវិធីរបស់យើង ។”

“សូមអរគុណចំពោះការបំភ្លឺ” ឆ្លើយតបដោយលោក អ៊ីនូហ្សី ។ “ជាក់ស្តែង យើងមិនយល់ស្របទេជាមួយនឹងសេចក្តីសម្រេចរបស់អង្គចៅក្រម ។ យើងយល់ថាមិនមានឯកសារចោទប្រកាន់ណាដាក់ជាភស្តុតាងទេ ។ នោះជាអ្វីដែលយើងបាននិយាយរហូតមក ។ វាមិនមែនជាភស្តុតាងនោះទេ ។ យើងត្រូវបានបង្ខំឲ្យគោរពតាមនីតិវិធីដែលបានដាក់ដោយអង្គជំនុំជម្រះ ជាមួយនឹងការគោរពតាមវិធាន ៨៧(៤) ... ។”

លោប្រធាន ណុន បានកាត់ផ្តាច់លោក អ៊ីនូហ្ស៊ី "យើងបានផ្តល់វេទិកាជូនទៅលោក ដើម្បីតាំងសំណួរទៅសាក្សីរូបនេះ ។ បញ្ហានេះបានសម្រេចរួចអស់ហើយ ។ លោកមិនគួរផ្តល់ការអធិប្បាយអ្វីបន្ថែមទៀតទេ ។" លោកប្រធាន បញ្ចប់ដោយរំឭកទៅលោក អ៊ីនូហ្ស៊ី ថា "ខំព្យាយាម និងឆ្លៀតឱកាសទៅធ្វើសេចក្តីថ្លែងពីអ្វីផ្សេងៗទៅ ។"

លោក អ៊ីនូហ្ស៊ី និយាយថា "ខ្ញុំដឹងថា ខ្ញុំមិនគួរធ្វើទេ ប៉ុន្តែខ្ញុំបង្ខំធ្វើបែបនេះសម្រាប់ឲ្យមានកំណត់ត្រា ។" "ខ្ញុំគ្រាន់តែនិយាយពីការជំទាស់របស់ខ្ញុំសម្រាប់ការកំណត់ត្រាទេ ។ ក្នុងករណីនេះដោយផ្អែកលើការសម្រេចនេះ ខ្ញុំនឹងមិនអាចសួរដោញដោលទៅលើសាក្សីនេះទេ ។"

លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ និយាយទៅកាន់លោក អ៊ីនូហ្ស៊ី ថា "ប្រហែលជាលោកមានការភាន់ច្រឡំ ។ អង្គជំនុំជម្រះមិនបានសម្រេចថា លោកមិនអាចយោងទៅរកឯកសារនេះទេ ។ លោកអាចយោងទៅរកឯកសារនេះបាន ប៉ុន្តែវាមិនមែនជាភស្តុតាងទេ វាជាដីការបស់សហចៅក្រមស៊ើបអង្កេត ។ ហេតុដូច្នេះ លោកអាចយោងទៅរកឯកសារនេះបាន ។ លោកយល់ច្បាស់ទេ? ទីពីរ" បន្តដោយចៅក្រម ខាតវ៉ាយថ៍ "លោកប្រធាននឹងសម្រេចថាតើលោកអាចសួរសំណួរទៅសាក្សីដោយផ្អែកលើដីការបស់សហចៅក្រមស៊ើបអង្កេត ប្រសិនបើមានចំណុចណាពាក់ព័ន្ធទៅនឹងសំណួររបស់លោក ។ តើលោកច្បាស់ទេ? " សួរបញ្ជាក់ម្តងទៀត ។

"និយាយដោយស្មោះ គឺវាមិនច្បាស់ទេ ។" និយាយដោយលោក អ៊ីនូហ្ស៊ី ។

"អញ្ចឹងគឺថា លោកអាចធ្វើអ្វីតាមដែលលោកចង់ ។ លោកអាចសួរទៅសាក្សីដោយផ្អែកលើឯកសារនេះ ឬក៏មិនផ្អែកបាន? " ឆ្លើយតបដោយចៅក្រម ខាតវ៉ាយថ៍ ។

លោក អ៊ីនូហ្ស៊ី ពន្យល់ថា "ខ្ញុំមានន័យថា ដីកានោះ គឺមានអង្គហេតុ ហើយអង្គហេតុនោះអាចជាភស្តុតាង ។ នេះជាមូលហេតុដែលមិនច្បាស់សម្រាប់ខ្ញុំ ។ ក្នុងករណីនេះ ខ្ញុំនឹងមិនបន្តការសួរទេ ។ ខ្ញុំនឹងផ្តល់វេទិកាជូនទៅសហសេវិករបស់ខ្ញុំដែលចង់បញ្ចេញយោបល់ពីបញ្ហាទាក់ទងនឹងការជម្លៀសចេញពីភ្នំពេញ ។ ដូច្នេះ ឥឡូវខ្ញុំផ្តល់ពេលវេលានេះទៅលោក នួន ជា ។"

## សហមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ផ្តល់តួនាទីទៅកូនក្តីរបស់គាត់

ទាំងអង្គជំនុំជម្រះ ទាំងសាលសាធារណៈ មានការភ្ញាក់ផ្អើលជាមួយនឹងលោក អ៊ីនូហ្ស៊ី ដែលបានប្រកាសថា នឹងផ្តល់វេទិកាជូនទៅកូនក្តីរបស់គាត់ជនជាប់ចោទ នួន ជា ។ លោក លីសាក់ ក្រោកឈរឡើង ហើយបាននិយាយទៅកាន់តុលាការថា ។ "ខ្ញុំជឿជាក់ថា យើងធ្លាប់បានជួបបញ្ហានេះពីមុនមកហើយ មុនពេលដែលឲ្យជនជាប់ចោទផ្តល់យោបល់ ។ ប្រសិនបើលោក នួន ជា ចង់ធ្វើការសួរ

ដេញដោលទៅលើបញ្ហានេះដោយខ្លួនឯងផ្ទាល់ មិនអីទេ ។ ប៉ុន្តែលោកមិនគប្បីសួរសំណួរទៅសាក្សីនៅក្នុងឱកាសនេះ ដើម្បីបង្ហាញពីទស្សនៈរបស់ខ្លួនទៅលើសាក្សីឡើយ ។»

លោកស្រី ហ្វូត ក្រោកឈរ និងនិយាយទៅកាន់តុលាការនៅក្នុងការស្រុះស្រួលថា «យើងមានគោលជំហរដូចគ្នាដែរ... លោក នួន ជា មិនអាចប្រើប្រាស់ពេលវេលារបស់តុលាការដើម្បីថ្លែងអ្វីដែលគាត់ចង់នោះទេ ។»

លោក អ៊ីនូហ្សី ឆ្លើយតបវិញ «លោក នួន ជា គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការពារខ្លួនរបស់គាត់ ។ គាត់ជាផ្នែកមួយដ៏សំខាន់ក្នុងក្រុមការពារក្ដីនេះ ។ គាត់ចង់បញ្ជាក់យោបល់មួយចំនួនទាក់ទងនឹងសក្ខីកម្មខាងដើមដែលគាត់ចង់ ។ ខ្ញុំយល់ថាហេតុអ្វីអង្គជំនុំជម្រះ មិនចាប់អារម្មណ៍ ពេញចិត្តលើអ្វីដែលគាត់បាននិយាយដើម្បីការជួយជ្រោមជ្រែងទៅរកការពិត ប្រសិនបើវាពិតទៅនឹងអ្វីដែលលោក នួន ជា សុំធ្វើការបញ្ចេញយោបល់បញ្ជាក់ពីការពិត ហើយគាត់នឹងសុខចិត្តឲ្យមានការដាក់សំណួរទៅលើគាត់ ។ ថ្ងៃនេះយើងមានពេលវេលាគ្រប់គ្រាន់ ដូចដែលខ្ញុំបាននិយាយហើយ គឺខ្ញុំនឹងផ្ដល់ពេលវេលារបស់ខ្ញុំនេះ ។

លោក លីសាក់ ក្រោកឈរម្ដងទៀត ហើយនិយាយ «ប្រសិនលោក នួន ជា ចង់សួរទៅលើបញ្ហានេះដោយខ្លួនលោកផ្ទាល់វាមិនជាបញ្ហាទេ ប៉ុន្តែចំពោះកាលវិភាគមួយខ្ញុំសូមស្នើកុំឲ្យមានបញ្ហានេះកើតឡើងនៅពាក់កណ្ដាលសក្ខីកម្មបែបនេះទេ ។»

លោកស្រី ហ្វូត ឯកភាពម្ដងទៀត «យើងគាំទ្រនូវគោលជំហររបស់សហព្រះរាជអាជ្ញា ។» និយាយដោយលោកស្រី ក្នុងនាមជាមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ។ លោកស្រី បានបន្ថែម «ប្រសិនបើលោក នួន ជា ចង់ឆ្លើយទៅនឹងសំណួរយើងយល់ព្រម ប៉ុន្តែវាប្រហែលមិនមែនជាពេលសមស្របនោះទេ ។»

លោក អ៊ីនូហ្សី ឆ្លើយតបថា «វាសមហេតុផលហើយនូវអ្វីដែលយើងធ្វើនៅពេលនេះ គឺនៅអំឡុងពេលផ្ដល់សក្ខីកម្មរបស់សាក្សី ។ គាត់អាចឆ្លើយតប និងបញ្ចេញជាយោបល់ ។ ខ្ញុំមិនយល់ថាមូលហេតុអ្វីដែលយើងត្រូវចាំរហូតដល់សាក្សីត្រឡប់ទៅវិញនោះទេ ។ យើងទាំងអស់គ្នានៅទីនេះយើងមានពេលវេលា ហើយវាក៏សមហេតុផលដែលត្រូវធ្វើនៅពេលនេះដែរ ។»

លោកប្រធាន ណុន បន្ទាប់ពីពិភាក្សាជាមួយចៅក្រមពីរបីនាទីមក លោកបានប្រកាសថា «អង្គជំនុំជម្រះ អនុញ្ញាតឲ្យជនជាប់ចោទតាំងសំណួរទៅសាក្សី ដោយឆ្លងកាត់យើងជាប្រធានអង្គជំនុំជម្រះសាលាដំបូងសិន ។» មុននឹងជូនម៉ៃក្រូទៅលោក នួន ជា និងអនុញ្ញាតឲ្យនិយាយ លោកប្រធាន ណុន

ជម្រាបទៅកាន់សាក្សីថា លោកមិនអាចឆ្លើយសំណួរណាឡើយ រហូតដល់មានការអនុញ្ញាតពី យើងជាចៅក្រមសិនចាំឆ្លើយ ។

## ជនជាប់ចោទ នួន ជា ថ្លែងទៅកាន់តុលាការ

ជនជាប់ចោទ នួន ជា ជាលើកដំបូងដោយសារតែវាជាពាក់កណ្ដាលខែមេសា បានថ្លែងទៅកាន់តុលាការ ដោយពាក់វ៉ែនតាជ័រពណ៌ទឹកប្រាក់ ។

នៅក្នុងសម្ដែងដ៏ធូន់ គាត់ចាប់ផ្ដើម «សូមគោរពបងប្អូនរួមជាតិ និងសូមគោរពលោកប្រធាន ។ ខ្ញុំសូមនិយាយពីរឿងជម្លៀសប្រជាជនដោយបន្ទំ ។ ខ្ញុំសូមធ្វើការឆ្លើយតបមួយចំនួនទៅនឹងសក្ខីកម្មរបស់សាក្សីរូបនេះ និងសាក្សីទាំងប៉ុន្មានកន្លងមកនេះ ទាក់ទងនឹងរឿងជម្លៀសប្រជាជន ។ លោកសាក្សីបានផ្ដល់នូវហេតុផលសមរម្យខ្លះៗពីការជម្លៀសប្រជាជនចេញពីទីក្រុង គឺដើម្បីចៀសពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក ភាពអត់ឃ្លាន និងសង្គ្រាមផ្ទៃក្នុង ។ លោកសាក្សីមិនបានដឹងច្បាស់ ឬដឹងពីហេតុផលច្រើនជាងនេះទេ ដែលធ្វើឲ្យគាត់យល់ថា ឬមធ្យោបាយជម្លៀសនេះ គឺមិនល្អទៅវិញ ។ ខ្ញុំសូមធ្វើការឆ្លើយតបដូចតទៅ៖ ជាដំបូង ខ្ញុំសូមជម្រាបថា យើងផ្ទាល់ជាអ្នកចាញ់សង្គ្រាម ហើយយើងក៏ត្រូវបានចោទប្រកាន់ពីការជម្លៀសប្រជាជន ។ សកម្មភាពដែលកំពុងមានពេលបច្ចុប្បន្ននេះ គឺដូចនឹងការជម្លៀសបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ខ្ញុំសូមនិយាយទៅកាន់ប្រជាជនដែលក្រីក្រ ដែលត្រូវបានជិះជាន់ ថ្កោលទោស និងធ្វើទុក្ខបុកម្នេញដល់អាយុជីវិតដោយអ្នកមានលុយ មានបុណ្យសក្ដិ ដែលកំពុងប្លន់ដីធ្លីស្រែចម្ការ... ។»

លោកប្រធាន ណុន បានកាត់ថា «ការថ្លែងរបស់លោកនេះ គឺចាកឆ្ងាយពីកិច្ចដំណើរការនីតិវិធីសវនាការថ្ងៃនេះហើយ ។» «អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើសេចក្ដីថ្លែងការណ៍ណាដែលក្រៅពីអង្គហេតុឡើយពាក់ព័ន្ធទៅនឹងអ្វីដែលសាក្សីបានដឹង... ក្នុងវេទិកានេះ លោកមិនត្រូវបានអនុញ្ញាតឲ្យធ្វើអ្វីស្រេចតែចិត្តលោកទេ... តើលោកមានសំណួរអ្វីពាក់ព័ន្ធទៅនឹងសាក្សីរូបនេះដែរឬទេ ទាក់ទងអង្គហេតុក្នុងសំណុំរឿង០០២ទាំងមូល ឬទាក់ទងទៅនឹងការដឹងរបស់សាក្សីរូបនេះ ដែលបានផ្ដល់សក្ខីកម្មរយៈពេលមួយថ្ងៃកន្លះមកហើយនេះ?»

ជនជាប់ចោទ នួន ជា ឆ្លើយតបថា «ខ្ញុំសូមនិយាយពីការជម្លៀសប្រជាជន ។»

លោកប្រធាន ណុន បានបង្អាក់គាត់ម្ដងទៀត ហើយនិងបិទម៉ៃក្រូរបស់គាត់ ដោយប្រាប់គាត់ថា «ប្រសិនបើលោកគ្មានសំណួរទេ អញ្ចឹងយើងមិនអនុញ្ញាតឲ្យលោកនិយាយទេ ។» យ៉ាងណាក៏ដោយ

ជនជាប់ចោទ នួន ជា នៅតែបន្តនិយាយទៅកាន់អង្គចៅក្រម ។ ថ្វីបើលោកប្រធាន ណុន បានបិទម៉ៃក្រូហើយ តែពាក្យរបស់គាត់បានឮខ្ទរពេញអង្គជំនុំជម្រះ ។

ទោះបីជាពាក្យរបស់ជនជាប់ចោទ នួន ជា មិនត្រូវបានបកប្រែជាភាសាអង់គ្លេស និងបារាំងក៏ដោយ ។ អ្នកភូមិដែលមើលពីសាលសាធារណៈ នៅតែអាចឮ និងយល់នូវអ្វីដែលគាត់និយាយដែរ ។ អ្នកខ្លះមើលហើយស្តាប់ដោយបញ្ចេញដោយភ្ញាក់ផ្អើល ។ ឯខ្លះទៀតខ្សឹបខ្សាវជាមួយអ្នកភូមិគ្នាឯងដែលនៅជិតគ្នា ។

លោកប្រធាន ណុន បានប្រកាសថា «លោក នួន ជា លោកមិនត្រូវបានអនុញ្ញាតឲ្យនិយាយទៀតឡើយ ។»

សហមេធាវីអន្តរជាតិការពារក្តី នួន ជា លោក ម៉ៃខល ផេសមិន ក្រោកឈរហើយបាននិយាយទៅកាន់តុលាការ ។ «លោកប្រធាន ពាក្យរបស់កូនក្តីរបស់ខ្ញុំមិនមានការបកប្រែជាភាសាអង់-គ្លេសទេ ។ ប្រហែលយើងគប្បីសុំឲ្យមានការបកប្រែឥឡូវនេះ ។ ខ្ញុំគិតថាវាមានការពាក់ព័ន្ធជាមួយគ្រប់អ្នកដែលមិនអាចនិយាយភាសាខ្មែរបាន ឲ្យដឹងពីអ្វីដែលកូនក្តីខ្ញុំបាននិយាយ ពិសេសគឺអ្វីៗដែលកូនក្តីខ្ញុំបាននិយាយ គប្បីតែឮ និងមានការបកប្រែ» សំណូមពរដោយលោក ផេសមិន ។

លោកប្រធាន ណុន បានឆ្លើយតបថា «កូនក្តីរបស់លោកមិនត្រូវអនុញ្ញាតឲ្យនិយាយឡើយ ។»

«តែម្តងទៀត លោកប្រធាន ខ្ញុំមិនបានដឹងថា កូនក្តីរបស់ខ្ញុំនិយាយពីអ្វីទេ» ឆ្លើយតបដោយលោក ផេសមិន ។ «វាពុំមានការបកប្រែទេ ហើយខ្ញុំជឿថា វាក៏មានប្រយោជន៍ក្នុងការបកប្រែសម្រាប់លោកចៅក្រមអន្តរជាតិដែរ ។ ឥឡូវនេះ អ្វីដែលយើងទាំងអស់គ្នាដឹង គឺអ្វីដែលលោកបាននិយាយ តែអ្វីដែលកូនក្តីខ្ញុំបាននិយាយ គឺខ្ញុំមិនយល់… ខ្ញុំចង់ដឹងនូវអ្វីដែលកូនក្តីរបស់ខ្ញុំបាននិយាយ» បន្ថែមដោយលោក ផេសមិន ។

លោកប្រធាន ណុន ឆ្លើយទៅវិញថា «បើលោកមេធាវីមិនយល់ពីអ្វីដែលគាត់បាននិយាយទេ អញ្ជើញលោកសាកសួរទៅមេធាវីជាតិការពារក្តីលោក នួន ជា ទៅបានហើយ ។» «តើលោកមានសំណួរដើម្បីសួរទៅសាក្សីដែរឬទេ? » សួរដោយលោកប្រធាន ណុន ។

លោក ផេសមិន បានជម្រាបទៅអង្គជំនុំជម្រះថា មេធាវីជាតិការពារក្តីលោក នួន ជា មានសំណួរមួយចំនួនសម្រាប់សួរទៅសាក្សី ។ មុននឹងអង្គុយចុះវិញ លោកបានជម្រាបថា នួន ជា ស្នើសុំការអនុញ្ញាតត្រឡប់ទៅបន្ទប់ឃុំខ្លួនដើម្បីស្តាប់សវនាការ ។ «ខ្ញុំពុំឃើញនូវហេតុផលណាដែលឲ្យកូនក្តីរបស់ខ្ញុំនៅក្នុងសវនាការនេះទេ ប្រសិនបើគាត់មិនបានអនុញ្ញាតឲ្យនិយាយដូច្នេះ» បន្ថែមដោយលោក ផេសមិន ។

ក្រោយមកលោកប្រធាន ណុន បាននិយាយទៅកាន់ជនជាប់ចោទ «លោក នួន ជា នេះពិតជាការសុំរបស់លោកដែលលោកទៅបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមមែនឬ?»

«បាទ ពិតមែនហើយ ។ ប្រសិនបើមិនឲ្យខ្ញុំនិយាយទេ អញ្ចឹងខ្ញុំសូមទៅនៅខាងក្រោមវិញ» ឆ្លើយតបដោយលោក នួន ជា ។ លោកប្រធាន ណុន បានអនុញ្ញាតឲ្យគាត់ធ្វើដូច្នេះ ។

## សហមេធាវីជាតិការពារក្តីលោក នួន ជា លោក សុន អរុណ ធ្វើការសួរដេញដោយលើសាក្សី យុន គីម ពីរឿងព្រះសង្ឃ និងការទម្លាក់គ្រាប់បែករបស់អាមេរិក

ជាមួយនឹងការសួរដេញដោលកាលពីពេលថ្ងៃនេះបានស្ងប់ហើយ លោក សុន អរុណ មេធាវីជាតិការពារក្តីលោក នួន ជា បានតាំងសំណួរទៅកាន់លោក គីម ដែលកំពុងមើលដោយស្ងៀមស្ងាត់ ។ ជាមួយនឹងទម្លាប់របស់គាត់ដែលមានក្រដាសកត់ត្រា និងវ៉ែនតាពណ៌ទឹកប្រាក់ លោក អរុណ ចាប់ផ្តើមសួរទៅកាន់សាក្សីឲ្យជួយបំភ្លឺពីមូលហេតុនៃការសឹករបស់ព្រះសង្ឃ នៅក្នុងភូមិភាគរបស់គាត់ ។

លោក គីម ឆ្លើយតបថា «នៅឆ្នាំ១៩៧៦ ព្រះសង្ឃនៅតាមវត្តនីមួយៗបានសឹក ។ ហើយដោយមានការបញ្ជាក់ពីអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យ ។» គាត់ពន្យល់ថា គេធ្វើបដិវត្តន៍តែម្តងទេ ហើយសាសនាអីក៏បំបាត់ជាមួយគ្នានឹងការធ្វើបដិវត្តន៍ដែរ ។ «យើងចង់ចៀសវាងនូវការធ្វើអ្វីដដែលៗដូចប្រទេសចិនទេ ដែលធ្លាប់មានបដិវត្តន៍ ហើយបន្ទាប់មកមានការធ្វើបដិវត្តន៍វប្បធម៌ម្តងទៀត ។»

លោក អរុណ សួរទៅលោក គីម ថាតើ នួន ជា បានពិភាក្សាពីរឿងខ្មាំងនៅពេលប្រជុំក្នុងឆ្នាំ១៩៧៣ដែរឬទេ? «ដោយយើងដឹងថាមានខ្មាំងអាមេរិក វៀតណាម និងខ្មាំងផ្ទៃក្នុង» ឆ្លើយតបដោយលោក គីម «វាជាទម្លាប់ធម្មតាទៅហើយនៃការពិភាក្សាអំពីសភាពការណ៍ខ្មាំង ដែលជាផ្នែកមួយនៅក្នុងចំណុចនេះ ។»

«តើលោកមានបានជួបលោក នួន ជា នៅថ្ងៃក្រោយមកទៀតដែរឬទេ?» សួរដោយលោក អរុណ ។ លោក គីម និយាយថា លោកមិនដែលបានជួបថ្នាក់ដឹកនាំណាក្រៅពីលោក នួន ជា ទេ ហើយគាត់ជាមនុស្សតែម្នាក់គត់ដែលគាត់បានជួបនៅក្នុងកិច្ចប្រជុំឆ្នាំ១៩៧៣ ។ «នៅពេលដែលជួបលោក នួន ជា គឺយើងនៅក្នុងសិក្ខាសាលា ហើយគាត់នៅលើវេទិកា ។ យើងអង្គុយនៅនឹងតុខាងក្នុងសាល កាលនោះមានមេឃុំមកពីបីស្រុក អញ្ចឹងគឺមានមនុស្សមិនច្រើនទេដែលបានមកចូលរួម ។»

បន្តសំណួរដោយលោក អរុណ «អញ្ចឹងលោក មិននិយាយជាមួយគាត់ទេឬ?» «បាទ ជាការពិតណាស់» តបវិញដោយលោក គីម ។

«តើលោកយល់ឃើញយ៉ាងម៉េចដែរចំពោះលោក នួន ជា? គាត់ជាមនុស្សអាក្រក់? មនុស្សឃោរឃៅ? ជាមនុស្សដែលចូលចិត្តតែការកាប់សម្លាប់? ឬក៏គាត់ជាមនុស្សល្អត្រឹមត្រូវដែលគួរឲ្យគោរពរាប់អាន?» សួរដោយលោក អរុណ ។

លោក គីម ឆ្លើយថា «គាត់ជាមនុស្សល្អ សមជាអ្នកដឹកនាំ ពីព្រោះនៅក្នុងភាសានិយាយស្តីក្តីការណែនាំក្តី គាត់តម្រង់ទិសមួយទៅឲ្យយ៉ាងម៉េច ក្នុងតួនាទីជាកម្មាភិបាលត្រូវមានលក្ខណៈល្អប្រសើរ ហើយឲ្យមានការជួបជាមួយនឹងប្រជាជន ។»

«តើលោកធ្លាប់បានជួបប្រទះផ្ទាល់ នឹងការទម្លាក់គ្រាប់បែកដោយអាមេរិកដែរឬទេ?» សួរដោយលោក អរុណ ។ លោក គីម និយាយថាអត់ទេ ប៉ុន្តែគាត់ធ្លាប់តែឮថា អាមេរិកទម្លាក់គ្រាប់បែកជាច្រើនដង ។ «នៅក្នុងឆ្នាំ១៩៧២» គាត់បានបកស្រាយថា «វាមានការលំបាកណាស់ក្នុងការស្វែងរកស្ថានណាមួយនៅក្នុងខេត្តក្រចេះ ដែលនៅពេញទាំងមូលនោះ ពីព្រោះវាត្រូវបានបំផ្លាញដោយគ្រាប់បែកអស់ហើយ ។» បន្ទាប់មកគាត់បានផ្តល់ជាឧទាហរណ៍ជាច្រើននូវគ្រាប់បែកដែលបានធ្លាក់មកចំកន្លែងផ្សេងៗគ្នាក្នុងខេត្តក្រចេះ ។ ថ្វីបើគាត់មិនដែលជួបប្រទះនូវការទម្លាក់គ្រាប់បែកផ្ទាល់ក៏ដោយ តែគាត់ធ្លាប់បានឮសម្លេងយន្តហោះដែលហោះកាត់ក្បាលគាត់ ហើយទម្លាក់គ្រាប់នៅពីចម្ងាយ ។

នៅពេលមានសំណួរសួរអំពីបញ្ហានៅក្នុងប្រទេស មុនពេលដែលវៀតណាមវាយលុកចូលនៅខែមករា ឆ្នាំ១៩៧៩ លោក គីម បានពន្យល់ថា ពេលនោះគាត់នៅភូមិដងទង់ ជាមួយនឹងប្រជាជនថ្មី ៣០គ្រួសារ ។ គាត់និយាយថា គាត់បានឃើញគ្រាប់ផ្លោងធ្លាក់មក ហើយអញ្ជើងគាត់ក៏បានឲ្យអ្នកភូមិទាំងគ្រួសារៗភៀសខ្លួនចេញទៅ ។ លោក គីម បន្តទៀតថានៅថ្ងៃបន្ទាប់ លោកបានឃើញវៀតណាមមកពេញ ។ លោករៀបរាប់ថា «ពេលនោះយើងសប្បាយក៏មិនសប្បាយ គឺអារម្មណ៍យើងច្របូកច្របល់តែម្តង ។» លោក គីម ជម្រាបទៅតុលាការថា បន្ទាប់មកទៀតគាត់ត្រូវបានចាប់ខ្លួនដោយកងទ័ពវៀតណាម និងជាប់ឃុំឃាំងនៅវៀតណាមអស់រយៈពេល៥ខែ ។

ដូច្នេះលោក អរុណ បានបញ្ចប់នូវការសាកសួររបស់គាត់ ។

កិច្ចបន្ត គឺជាវេទិកាសម្រាប់ក្រុមសហមេធាវីជាតិការពារក្តីលោក អៀង សារី ។ គាត់បានថ្លែងអំណរគុណទៅលើសក្ខីកម្មរបស់លោក គីម ដែលបានតាំងនាមជាកូនក្តីរបស់គាត់ អៀង សារី និងជម្រាបទៅតុលាការថា លោកមិនមានសំណួរទេ ។

## ការបញ្ចប់សំណួរលើសក្ខីកម្មរបស់សាក្សី យុន គីម ពីសហមេធាវីអន្តរជាតិការពារក្ដីលោក ខៀវ សំផន លោក អាកទួរ វែកកែន ទៅលើរឿងដែលលោក គីម ចូលបដិវត្តន៍

លោក អាកទួរ វែកកែន សហមេធាវីការពារក្ដីលោក ខៀវ សំផន ប្រកាសថា ខ្លួនមានសំណួរតែពីរបីទេ ។

លោកបានជម្រាបទៅលោក គីម ថា គាត់«មានសំណួរដែលឆ្លល់ទៅលើចំណុចមួយ ដែលទាក់ទងនឹងការចូលបដិវត្តន៍របស់លោក ។» លោក គីម បានពន្យល់ថា គាត់ចូលបដិវត្តន៍បន្ទាប់ពី លន់ នល់ ឡើងកាន់អំណាចនៅឆ្នាំ១៩៧០ ។ គាត់បន្ថែមថា គាត់បានចូលបដិវត្តន៍ដោយឆន្ទៈខ្លួនផ្ទាល់ ។ នៅឆ្នាំ១៩៧១ ពេលដែលក្រុមខ្មែរក្រហមចូលមកជិតភូមិ ខ្ញុំបានជួបលោក ចែត ដែលគាត់ជាអ្នកឲ្យសៀវភៅពីរបីក្បាលមកខ្ញុំ ហើយប្រាប់ឲ្យខ្ញុំអានវាដោយខ្លួនឯងទៅ ។ លោក គីម បន្តថា ក្រោយពីការកោះប្រជុំជាហូរហែរមក គាត់បានប្រគល់តួនាទីឲ្យខ្ញុំធ្វើជាមេឃុំវត្សនៈ ។

លោក គីម បានពន្យល់ថា គាត់បានសម្រេចចិត្តចូលបដិវត្តន៍នេះ ដើម្បីស្វែងយល់ឲ្យស៊ីជម្រៅអំពីវា ដូច្នេះយើងអាចរៀនសូត្រពីអ្វីៗបានច្រើន ។ «ជាការពិតណាស់» គាត់និយាយថា «យើងត្រូវតែចេះប្រយត្ន័ប្រយែងបំផុត ។» គាត់បានក្លាយជាមិត្តភក្ដិរបស់ប្រធានៗកងពលយោធាលេខ៨១០ និង ៩២០ ។ លោក គីម និយាយថា អញ្ចឹងហើយនៅពេលនោះពួកគេត្រូវបានចាប់ខ្លួន គាត់ក៏បែកគ្នា ។

លោក វែកកែន បានជម្រាបទៅអង្គជំនុំជម្រះថា លោកអស់មានសំណួរទៀតហើយ ។

លោកប្រធាន ណុន បានអរគុណចំពោះលោក គីម ថាគាត់បានបញ្ចប់សក្ខីកម្មគាត់ហើយ ។ គាត់ប្រកាសពីសាក្សីបម្រុង TWC 321 ដែលនឹងចាប់ផ្ដើមផ្ដល់សក្ខីកម្មនៅបន្ទាប់ពេលសម្រាកនៅរសៀលនេះ ។

## ចាប់ផ្ដើមសក្ខីកម្មរបស់សាក្សី ខៀវ នៅ ដែលជាអតីតព្រះសង្ឃ និងជាមិត្តភក្ដិ តាម៉ុក

លោកប្រធាន ណុន ស្នើបង្គាប់ឲ្យនាំខ្លួនសាក្សីមកក្នុងអង្គជំនុំជម្រះ ដើម្បីបន្តកិច្ចដំណើរការនីតិវិធីឲ្យបានឆាប់រហ័ស ។

«តើលោកឈ្មោះអ្វី?» សួរដោយលោកប្រធាន ណុន ។ សាក្សីសួរវិញដោយញញឹម «តើអាចសុំសំណួរម្ដងទៀតបានទេ?»

សាក្សីបានប្រាប់ថា ឈ្មោះរបស់គាត់គឺ ខៀវ នៅ ។ ពេលដែលសួរពីថ្ងៃកំណើតរបស់គាត់ គាត់បានឆ្លើយថា «ខ្ញុំមិនដឹងពីថ្ងៃខែបារាំងយ៉ាងម៉េចទេ ។ ខ្ញុំកើតនៅថ្ងៃសៅរ៍» ហើយគាត់និយាយនិងជម្រាបទៅតុលាការថា ឥឡូវគាត់មានអាយុ៧៩ឆ្នាំហើយ ។

ពេលដែលសួរពីមុខតំណែងរបស់គាត់ លោក នៅ ឆ្លើយថា "ខ្ញុំគ្មានធ្វើអ្វីធំដុំទេ គ្រាន់តែមើលកូនប្រាំនាក់ និងមើលការខុសត្រូវជួយមនុស្សនៅក្នុងវត្ត ។" ប្រពន្ធរបស់គាត់ឈ្មោះ ងិន អឿន ហើយយើងមានកូនប្រាំមួយនាក់ ។

បន្ទាប់មកលោក នៅ បានអះអាងថា គាត់មិនមានចំណងញាតិលោហិតជាមួយនឹងភាគីណាមួយក្នុងរឿងក្ដីនេះទេ ហើយគាត់ក៏បានស្បថនៅចំពោះមុខតាដំបងដែកហើយដែរ ។ គាត់នៅនឹកឃើញថា គាត់ត្រូវបានសម្ភាសជាមួយសហចៅក្រមស៊ើបអង្កេតពីរដងនៅស្រុកអន្លង់វែង ប៉ុន្តែមិនបាននឹកឃើញពីថ្ងៃដែលសម្ភាសនោះទេ ។ លោក នៅ និយាយពីចម្លើយពីក្នុងការសម្ភាសគាត់ ដែលគាត់បានអានដែរក្នុងពេលថ្មីៗនេះ ប៉ុន្តែគាត់ជម្រាបទៅតុលាការថា "ខ្ញុំនៅមានអារម្មណ៍ថា ការកត់ត្រានេះនៅមិនទាន់ត្រឹមត្រូវទាំងស្រុងនោះទេ ។" ទោះបីជាលោកប្រធាន ណុន បានរកឃើញយ៉ាងខ្ជាប់ខ្ជួនច្រើនជាងនេះក៏ដោយ ក៏ឃើញចម្លើយរបស់គាត់មានតែពីរបីចំណុចប៉ុណ្ណោះដែលមិនត្រឹមត្រូវ ។

លោក ឧត្តម បានបង្អាក់ ដោយសួរថា "ហេតុអ្វីក៏អវត្តមានមេធាវីប្រឹក្សា ដើម្បីជួយទៅសាក្សី?"

"សាក្សី បានអះអាងថា គាត់មិនត្រូវការមានមេធាវីទេ" លោកប្រធាន ណុន ឆ្លើយតប ។ ជាចុងបញ្ចប់ក្នុងការសាកសួរសាក្សី លោកប្រធាន ណុន បានផ្ដល់វេទិកាជូនទៅជំនួយការសហព្រះរាជអាជ្ញាជាតិ លោក វើង ហ៊ិត ចាប់ផ្ដើមការសាកសួរ ។

## សហព្រះរាជអាជ្ញា ចាប់ផ្ដើមការសួរដេញដោលទៅលើសាក្សី ខៀវ នៅ

យោងតាមចម្លើយនៃបទសម្ភាសរបស់គាត់ជាមួយនឹង ក.ស.ច.ស លោក ហ៊ិត បានសួរទៅកាន់លោក នៅ ពីប្រវត្តិរបស់គាត់ជាមួយ តាម៉ុក ជាពិសេស គឺពេលដែលលោក នៅ ចំណាយពេលនៅវត្តជាមួយគាត់ ។

លោក នៅ ឆ្លើយថា "គាត់បួសជាព្រះសង្ឃរយៈពេលប្រហែល១០ឆ្នាំ" ។ លោក នៅ បានបន្ថែមទៀតថា យ៉ាងណាក៏ដោយបន្ទាប់ពីគាត់បានសឹក គាត់បានចាប់ផ្ដើមមានគ្រួសារ ។ យ៉ាងណាមិញ នៅពេលនោះលោក នៅ ទើបតែជាក្មេងប្រុសម្នាក់នៅឡើយ ហើយគាត់ពិបាកនឹងនឹកឃើញនៅឆ្នាំដែលកើតឡើងជាក់ស្ដែងទៀតដែរ ។ បើតាមគាត់ស្មានគឺវាកើតឡើងនៅក្នុងវង្វង់ឆ្នាំ១៩៤០ប្លាយ ។

លោក ហ៊ិត សួរថា "តើមានអ្វីកើតឡើងចំពោះលោក បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥?"

លោក នៅ បានឆ្លើយថា «លោកសង្ឃដែលចេញមកពីទីក្រុងភ្នំពេញ និងខេត្តតាកែវ បានមកជួបជុំគ្នា ហើយយើងឮថា អង្គការឲ្យយើងលាចាកសិក្ខាបទ យើងក៏បានធ្វើតាម ។»

«ក្រោយពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តើប្រជាជនធម្មតាអាចប្រតិបត្តិតាមសាសនារបស់គេបានដែរឬទេ?» សួរដោយលោក ហ៊ិត់ ។ «ពួកគេអាចប្រតិបត្តិបានតែមានកម្រិត» ឆ្លើយដោយលោក នៅ «ប៉ុន្តែខ្ញុំដឹងតែនៅក្នុងស្រុកត្រាំកក់មួយទេ ព្រោះខ្ញុំដឹងតែត្រឹមហ្នឹងប៉ុណ្ណោះ ។»

«តើលោកសង្ឃអាចប្រតិបត្តិតាមសាសនាព្រះពុទ្ធដែរឬទេ?»

លោក នៅ តបវិញថា «នៅពេលដែលខ្ញុំលាចាកសិក្ខាបទហើយ គឺមានលោកសង្ឃមិនច្រើនទេដែលនៅក្នុងវត្ត ក្រោយមក ខ្ញុំអត់បានដឹងច្បាស់ថាលោកសង្ឃដែលគង់នៅនោះ លាចាកសិក្ខាបទទៀតឬបែបណាឡើយ ។ ខ្ញុំសំដៅទៅវត្តពីរក្នុងស្រុក ត្រាំកក់ ។»

លោក ហ៊ិត់ បានសួរទាក់ទងទៅនឹង ការជម្លៀសប្រជាជនក្នុងស្រុក ត្រាំកក់ «តើលោកអាចប្រាប់យើងបានទេ ថាលោកឃើញអ្វីខ្លះនៅពេលនោះ?»

«ខ្ញុំឃើញការជម្លៀសពីវត្ត ចម្ប៉ា ទៅវត្តផ្សេងៗទៀត» ពន្យល់ដោយលោក នៅ «តែទាក់ទងនឹងការជម្លៀសពីភ្នំពេញ ឬ តាកែវ នោះខ្ញុំគ្រាន់តែបានឮពីព្រឹត្តិការណ៍នេះ ព្រោះខ្ញុំមិនបានឃើញផ្ទាល់ខ្លួនឯងទេ ។» លោក នៅ បន្តពន្យល់ថា គាត់បានដឹងអំពី ការជម្លៀសនៅភ្នំពេញ ពីបងប្អូនសាច់ញាតិដែលបានភៀសខ្លួនពីទីក្រុង ។ «ប្រជាជនរាប់ពាន់នាក់ត្រូវបានជម្លៀស» គាត់និយាយថា «លោកអាចឃើញមនុស្សពេញហ្នឹងគ្រប់ទីកន្លែង ។»

«តើលោកមានបានឃើញអ្នកជម្ងឺ ឬមនុស្សចាស់ជរាដែរឬទេ?» សួរដោយលោក ហ៊ិត់ ។

«ខ្ញុំមិនបានទៅ និងពិនិត្យពិច័យសព្វកន្លែងនោះទេ» ឆ្លើយដោយលោក នៅ ។

ពេលដែលសួរថា គាត់មានដឹងថា អ្នកណាជាអ្នកបង្កើតសហករណ៍ លោក នៅ ឆ្លើយថា «ជាទូទៅ យើងមិនមែនជាអ្នកនយោបាយ ឬអ្នកយកការណ៍អីទេ ។ យើងដឹងត្រឹមតែពាក្យថា អង្គការ ។ ប៉ុន្តែយើងមិនដឹងថា អ្នកណាជាអង្គការនោះទេ ។»

លោក ហ៊ិត់ ជម្រាបទៅលោកប្រធាន ណុន ថា គាត់បានបញ្ចប់នូវការសួរដេញដោលរបស់គាត់ហើយ ។

យើងសម្គាល់ឃើញថា វាជាពេលដែលសមល្មមនឹងសម្រាកហើយ លោកប្រធាន ណុន ជម្រាបទៅលោក នៅ ថា ការស្តាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ និងបង្គាប់ឲ្យលោកត្រឡប់មកអង្គជំនុំជម្រះវិញនៅថ្ងៃបន្ទាប់ គឺថ្ងៃព្រហស្បតិ៍ ទី២១ ខែមិថុនា ឆ្នាំ២០១២ នៅម៉ោងប្រាំបួនព្រឹក ។ បន្ទាប់មកលោកប្រធាន ណុន បានផ្អាកអង្គជំនុំជម្រះ ។ **-ចប់-**